# អន្តរប្រឹវ
## សម្លេងខ្មែរនៅបរទេស

# ការវិភាគ
## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ អំពីវិបស្សនាអប់រំចិត្ត (ត)

website ៖ www.hoksavann.org

ថ្ងៃទី១៣ មិថុនា ២០០៨



ដូចបានពោលមកហើយ វិបស្សនាប្រែថា ការឃើញច្បាស់នូវត្រៃលក្ខណ៍ក្នុងខន្ធ៥ ដោយមានពាក្យវិគ្គហ:ថា វិវិធាការេន អនិច្ចាទិវសេន បស្សតីតិ វិបស្សនា ប្រែថា បញ្ញាពិចារណាឃើញច្បាស់នូវខន្ធ៥ ដោយអាការៈផ្សេងៗ មានភាពមិនទៀងជាដើម ហៅថាវិបស្សនា ។ មួយទៀតថា វិសេសេន បស្សតីតិ វិបស្សនា ប្រែថា បញ្ញាឃើញពិសេស ហៅថា វិ-បស្សនា ។ អ្វីដែលហៅថាខ្លួន ? ព្រះពុទ្ធបានចែកនូវការកត់សំគាល់របស់មនុស្សសត្វ ថាខ្លួននោះគ្មានអ្វីក្រៅពីខន្ធ៥ឡើ-យ ។ ខន្ធ៥នោះគឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ។ បើចែកឲ្យខ្លីខន្ធ៥នេះចែកជារូបធម៌ និង នាមធម៌ ។ រូបខន្ធចាត់ជារូបធម៌ ឯវេទនាខន្ធ សញ្ញាខន្ធ សង្ខារខន្ធ និងវិញ្ញាណខន្ធ ទាំង៤នេះចាត់ជានាមធម៌ ។ ដូច្នេះក្នុងអត្ថបទធម៌ បើនិយាយថា រូបធម៌ និងនាមធម៌ គឺសំដៅយកខន្ធ៥នេះឯង ។ ខន្ធ៤ខាងចុងនេះបានជាចាត់ជានាមធម៌ ព្រោះមានឈ្មោះតែគ្មានរូប ។ នៅក្នុងគិរីមានន្ទសូត្រ ព្រះពុទ្ធបានសួរព្រះអានន្ទជាប្រស្នាថា ម្នាលអានន្ទ ខន្ធ៥ទៀងឬមិនទៀង បពិត្រព្រះអង្គដ៏ចំរើន ខន្ធ៥មិនទៀងទេ ចុះរបស់ណាមិនទៀង របស់នោះជាសុខឬជាទុក្ខ បពិត្រព្រះអង្គដ៏ចំរើន របស់ណាមិនទៀងរបស់នោះជាទុក្ខ ចុះរបស់ណាមិនទៀងជាទុក្ខ តើគួរសំគាល់ថាជារបស់ខ្លួន តើត្រឹមត្រូវឬទេ សូមទានមេត្តាប្រោស របស់ណាមិនទៀងជាទុក្ខ ពុំគួរសំគាល់ថាជាខ្លួនឡើយ របស់នោះជាអនត្តា មិនមែនខ្លួនឡើយ ។

តាមសំនួរនិងចម្លើយរបស់ព្រះពុទ្ធជាមួយព្រះអានន្ទនេះ បញ្ជាក់ថាខន្ធ៥នេះមានលក្ខណៈ៣យ៉ាងគឺ អនិច្ចំ ទុក្ខំ និង អនត្តា ។ ដូច្នេះអ្នកចំរើនវិបស្សនាត្រូវមានវិធីអនុវត្តបែបណាដើម្បីឲ្យឃើញការពិតនេះ ។ បើគ្រាន់តែស្តាប់ព្រះសង្ឃទេសនា ឬមើលសៀវ

គោចរធម៌អំពីត្រៃលក្ខណ៍នេះ ក៏មិនអាចឃើញត្រៃលក្ខណ៍នេះដែរ ។ មួយទៀត បើយកពាក្យត្រៃលក្ខណ៍មកទន្ទេញដដែលៗថា អនិច្ចំ ទុក្ខំ អនត្តា ក៏មិនអាចឃើញត្រៃលក្ខណ៍ធម៌ដូចគ្នា ។

មានគ្រូបង្រៀនអភិធម្មមួយក្រុមយល់ថា បើកំណត់តាមសតិបដ្ឋាន ដូចភ្នែកឃើញរូប ត្រចៀកឮសម្លេងជាដើម ហាក់ដូចជាទទួលស្គាល់ថា មានខ្លួនព្រោះអាការៈទាំងនេះជាបរមត្ថធម៌ ។ ការពិតគេមិនអាចកំណត់ឲ្យទៅជាបរមត្ថដូច្នេះបានទេ ព្រោះការឃើញជាបរមធម៌ ជាបញ្ញារបស់ព្រះអរិយបុគ្គល ដែលលោកឃើញការពិតនេះ ។ គេអាចសំគាល់បានតែភាពប្រាកដឡើងនៃអាការៈទាំងនោះ ព្រោះការកំណត់ដោយសតិសម្បជញ្ញៈក្នុងអារម្មណ៍ដែលកើតឡើង នាំមិនឲ្យចិត្តជាប់ក្នុងលោភៈ ឬក្នុងទោសៈ តែជាចិត្តឧបេក្ខា ។ កាលណាចិត្តជាឧបេក្ខា ជាចិត្តបរិសុទ្ធ អាចផុសបញ្ញាកើតឡើងពេលនោះ បើមានឧបនិស្ស័យ អាចឃើញបរមត្ថធម៌ពេលនោះតែម្តង ។ តាមវិជ្ជាផ្លូវលោកផ្នែកគីមីវិជ្ជា គេអាចឆ្លុះមើលឃើញនូវរបស់ល្អិត ដែលមើលនឹងភ្នែកធម្មតាមិនឃើញ ។ គេប្រើប្រដាប់សំរាប់ឆ្លុះ ហៅថាអតិសុខុមទស្សន៍ ។ ប៉ុន្តែអ្នកប្រតិបត្តិធម៌វិញ អាចមើលឃើញនូវបរមត្ថធម៌ ដោយផ្លូវវិបស្សនា ។

នៅពេលនេះ សូមរៀបរាប់អំពីសតិកំណត់ខ្យល់ដង្ហើមចេញចូលក្នុងឥរិយាបថទាំង ៤ និងអាយតនៈទាំង៦ ។ នៅក្នុងគីរីមានន្ទសូត្រលោកឲ្យកំណត់ខ្យល់ត្រង់ចុងច្រមុះ ចូលឲ្យកំណត់ថាចូល, ចេញឲ្យកំណត់ថាចេញ ។ ខ្យល់ចេញចូលឲ្យប្រព្រឹត្តទៅជាធម្មតាគ្រាន់តែកំណត់ដឹងប៉ុណ្ណោះ សូមកុំប្រឹងដកឬដកតិចៗ ដើម្បីកំណត់ឡើយ ។ ការមានសតិកំណត់ដឹងដូច្នេះ ដើម្បីធ្វើឲ្យចិត្តនឹង ដែលអាចឲ្យនីវរណធម៌ទាំង៥ មានកាមច្ឆន្ទៈជាដើមស្ងប់ ហើយឃើញការកើតរបស់សង្ខារតាមរយៈដង្ហើមចេញចូល ។ ឥរិយាបថដេកដើរឈរអង្គុយ ។ ឥរិយាបថដើរត្រូវតំកល់សតិទុកនៅនឹងចុងជើង បើជើងស្តាំឈានដើរ ត្រូវផ្ចង់សតិសំឡឹងត្រង់ចុងជើងស្តាំនោះ ហើយកំណត់ថាស្តាំឈាន ។ បើជើងឆ្វេងឈានដើរ ត្រូវផ្ចង់សតិសំឡឹងត្រង់ចុងជើងឆ្វេងនោះ ហើយកំណត់ថាឆ្វេងឈាន។ ឥរិយាបថឈរ ត្រូវតំកល់សតិទុកត្រង់រូបឈរនោះ រួចកំណត់ថាឈរ ។ ឥរិយាបថអង្គុយ ត្រូវកំណត់សតិទុកត្រង់រូបអង្គុយនោះ រួចកំណត់ថាអង្គុយ ។ ឥរិយាបថដេក ត្រូវកំណត់សតិទុកនៅនឹងរូបដេកនោះ រួចកំណត់ថាដេក ។ លក្ខណៈដែលផ្ចង់សតិកំណត់សំគាល់ឥរិយាបថទាំង៤ ព្រមទាំងបរិកម្ម ឬកំណត់ទៅតាមឥរិយាបថដូច្នេះ ជាមូលហេតុនាំឲ្យចំរើនប្រាជ្ញាស្មារតី ដើម្បីឲ្យបំបែរទឹកចិត្តឲ្យឃ្លាតចាកតណ្ហាទិដ្ឋិបន្តិចម្តងៗ ។ ចំណែកការកំណត់ពេលដែលអាយតនៈខាងក្នុងនិងខាងក្រៅប៉ះគ្នា ត្រូវកំណត់ដូចតទៅនេះ ។ រូបប៉ះនឹងភ្នែក ត្រូវផ្ចង់សតិទុកនៅនឹងកែវភ្នែក រួចកំណត់ថាឃើញរូប ។ សម្លេងបានប៉ះនឹងត្រចៀក ត្រូវផ្ចង់សតិទុកនឹងត្រចៀក រួចកំណត់ថាឮសម្លេង ។ ក្លិនមកប៉ះនឹងច្រមុះ

ត្រូវផ្ចង់សតិទុកនឹងច្រមុះ រួចកំណត់ថាធុំក្លិន ។ រសមកប៉ះនឹងអណ្តាត ត្រូវផ្ចង់សតិទុកនឹងអណ្តាត រួចកំណត់ថាដឹងរសជាតិ ។ ផោដ្ឋព្វៈ មកប៉ះនឹងកាយ ត្រូវផ្ចង់សតិទុកនឹងកាយ រួចកំណត់ថា ប៉ះពាល់ត្រូវ ។ ធម្មា (ធម្មារម្មណ៍) មកប៉ះនឹងមនោ ត្រូវផ្ចង់សតិទុកនឹងមនោ ឬកំណត់ថាដឹងអារម្មណ៍ (អារម្មណ៍បែបណាក៏ដោយ) ។ ការកំណត់ដូច្នេះ ដើម្បីឲ្យដឹងការប្រែប្រួលនៃរូបធម៌ និងនាមធម៌ ដែលជាលក្ខណៈរបស់ត្រៃលក្ខណ៍ធម៌ ។

ពេលកំពុងកំណត់ដង្ហើមចេញចូលតាមច្រមុះ បើមានហេតុការណ៍ណាកើតឡើង ដូចវេទនាជាសុខជាទុក្ខ ប្រព្រឹត្តទៅតាមផ្លូវកាយឬផ្លូវចិត្ត ត្រូវងាកទៅកំណត់វេទនានោះ ។ បើចិត្តនឹកគិតបែបណាមួយ ក៏ត្រូវងាកទៅកំណត់នូវអាការៈចិត្តនោះដូចគ្នា ។ នៅក្នុងគម្ពីរវិសុទ្ធិមគ្គផ្នែកសមាធិនិទ្ទេសអានាបានស្សតិ ការកំណត់ដង្ហើមចេញចូលជាតួសមថៈ ប៉ុន្តែនៅក្នុងសតិបដ្ឋាន ត្រង់កាយានុបស្សនាសតិបដ្ឋាន ជាតួវិបស្សនា ព្រោះខ្យល់ដង្ហើមចេញចូលជាកាយសង្ខារ ។ ការកំណត់ខ្យល់ដង្ហើមចេញចូលក្តី ការកំណត់តាមឥរិយាបថទាំង៤ក្តី ការកំណត់តាមអាយតនៈទាំង៦ មានការឃើញរូប និងឮសម្លេងក្តី ដើម្បីរំលត់លោភៈ ទោសៈ មោហៈ ព្រោះបើមិនមានសតិកំណត់ទេ អកុសលមូលទាំង៣នេះណាមួយអាចកើតឡើង ។ កាលណាបានកំណត់ចិត្តរមែងស្ងប់ ដែលជាគុណជាតិឈានទៅរកការដឹងច្បាស់នូវសង្ខារ ការកើតរលត់របស់សង្ខារមានខន្ធ៥ជាដើម ដែលជាត្រៃលក្ខណ៍ធម៌ ។ តើអ្វីជាដួងកែវកំណើតរបស់មនុស្សសត្វ ? ដួងកែវរបស់មនុស្សសត្វ គឺត្រៃលក្ខណ៍ធម៌ អនិច្ចំ ទុក្ខំ អនត្តានេះឯង ។ បើមនុស្សសត្វឃើញច្បាស់នូវត្រៃលក្ខណ៍ធម៌ ពួកគេនឹងរួចចាកទុក្ខ ព្រោះបើឃើញត្រៃលក្ខណ៍ធម៌ សត្វលោកនឹងស្គាល់ទុក្ខច្បាស់ គឺការកើតឡើងនៃខន្ធ៥ជាតួទុក្ខ ។ ក្នុងធម៌អារាធនាព្រះធម្មកបិកសំដែងធម៌ទេសនាថា ត្រៃលោកលោកត្រៃលក្ខណ៍ សង្សារចក្រវិលមិនដល់ អវិជ្ជាកឫសគល់ ជាបច្ច័យនៃសង្ខារ ។ ផឹកអម្រឹតជាតិ រសនិព្វានតាមធម្មតា ។ ផឹកអម្រឹតជាតិ គឺប្រតិបត្តិតាមមគ្គប្រកបដោយអង្គ៨ បានសម្រេចផល គឺព្រះនិព្វាន ជាការរំលត់ទុក្ខ ។ ការប្រតិបត្តិតាមមគ្គទាំង ៨ គឺការដឹកល់សតិកំណត់តាមសតិបដ្ឋានទាំង៤ដូចពោលមកហើយ ។ សាប៊ូសំរាប់ដុះសំអាតរូបកាយ ចំណែកសតិបដ្ឋាន៤សំរាប់សំអាតផ្លូវចិត្ត ធ្វើចិត្តបរិសុទ្ធ ទើបបញ្ញាកើតឡើង ឃើញអរិយសច្ច៤ ជាធម៌រំលត់ទុក្ខ ។៚

❄ ❄

❄